សមាគមសេដ្ឋកិច្ចកម្ពុជា
CAMBODIAN ECONOMIC ASSOCIATION

# ការគ្រប់គ្រងចំណូលឧស្សាហកម្មនិស្សារណកម្ម៖ បទពិសោធន៍សម្រាប់ប្រទេសកម្ពុជា[១]

វេទិកាស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា
សង្ខេបគោលនយោបាយ 2013, លេខ 02*

*“ថាតើចំណូលពីវិស័យប្រេង និងឧស្ម័ន អាចជួយពង្រីកពិពិធកម្មសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រដល់កម្ពុជាដែរឬទេ គឺជាបញ្ហាយ៉ាងសំខាន់សម្រាប់ប្រទេសកម្ពុជាក្នុងរយៈពេលមធ្យម"។*

*ប្រសាសន៍របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន*
*នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា[២]*

## សេចក្តីផ្តើម

ប្រទេសកម្ពុជារំពឹងថា ចំណូលរបស់ខ្លួននឹងកើនឡើងយ៉ាងខ្លាំង នៅពេលដែលគេអាចទាញយកធនធានប្រេង និងឧស្ម័ននៅកម្ពុជាបាននៅឆ្នាំ២០១៦។តាមការប្រមើលឃើញ សេដ្ឋកិច្ចនឹងមានអនាគតភ្លឺត្រចះ ប៉ុន្តែក្នុងរយៈពេលខ្លី កម្ពុជាអាចជួបបញ្ហាប្រឈមធំៗ ទាំងផ្នែកស្ថាប័ន និងសេដ្ឋកិច្ច។ បញ្ហាសំខាន់បំផុតមួយគឺ តើត្រូវគ្រប់គ្រង និងប្រើប្រាស់ចំណូលនេះយ៉ាងណា ដើម្បីឲ្យមានផលិតភាពសម្រាប់មនុស្សជាច្រើនជំនាន់នោះ? កម្ពុជា ក៏ដូចជាប្រទេសសម្បូរធនធានឯទៀតដែរ ត្រូវត្រៀមខ្លួនឲ្យបានល្អមុននឹង ប្រាក់ចំណូលពីប្រេង និងឧស្ម័ននេះ ហូរស្រោចមកដល់។ ដោយមូលហេតុនេះហើយ ការស្វែងរកគំរូសម្រាប់គ្រប់គ្រង និងប្រើប្រាស់ចំណូលបានពីឧស្សាហកម្មនិស្សារណកម្ម (EI) គឺជា ការងារដ៏មានសារសំខាន់ណាស់ និងដល់ពេលវេលាហើយ។

រូបភាព១៖ ប្លុកសម្រាប់រុករកប្រេងនិងឧស្ម័ននៅតំបន់ដីគោក និងសមុទ្រ




ប្រភព៖ អាជ្ញាធរប្រេងកាតជាតិកម្ពុជា (២០១១)

តំបន់មានប្រេង ជាសក្តានុពលមួយចំនួននៅកម្ពុជាមានបង្ហាញជារង្វង់ក្រហមនៅក្នុងរូបភាព ១។ ការខួងស្រាវជ្រាវ និងការប៉ាន់ស្មានបណ្តោះអាសន្ននៅប្រទាំងប្រទើស និងមិនទាន់ច្បាស់នៅឡើយ។ ប៉ុន្តែការប៉ាន់ស្មានព្រាងមួយបានបង្ហាញថា អាចមានប្រេងរហូតដល់ ២ពាន់លានធុង និងឧស្ម័ន ២៨៣ពាន់លានម៉ែត្រគូប ដែលអាចបូមយកបាន (UNDP 2006: 10)។ ជាឧទាហរណ៍ គេប៉ាន់ស្មានថា គ្រាន់តែប្រេងអាចបូមយកបានពីប្លុក A តែមួយគត់ អាចមានប្រមាណ ២០០-២៥០ពាន់ធុងក្នុងមួយថ្ងៃ។ ដូច្នេះ បើសិនផលិតកម្មប្រេងគ្រោងធ្វើឡើងក្នុងរយៈពេល ២០-២៥ឆ្នាំ ហើយធនធានប្រេងទាំងអស់ដែលគេប៉ាន់ស្មានថាអាចយកបាននោះ គឺអាចបូមបានជាក់ស្តែងមែន ប្រាក់ចំណូលពីប្រេងក្នុងគ្រប់ប្លុកទាំងអស់ អាចមានដល់ ៦ពាន់លានដុល្លារក្នុងមួយឆ្នាំ បើគិតតាមតម្លៃប្រេង ៥០ដុល្លារក្នុងមួយធុង។ ចំណូលនេះធំណាស់ បើធៀបនឹង ផសស ១៤,០៦ពាន់លានដុល្លារដែលកម្ពុជាសម្រេចបាននៅឆ្នាំ២០១២ (World Bank 2013)។[៣] ជាការពិត យើងត្រូវការចំណាយពេលច្រើនឆ្នាំ ដើម្បីទាញយកប្រេង និងឧស្ម័ន ឲ្យបានពេញលេញ។

ចំណូលពីឧស្សាហកម្ម និស្សារណកម្មនៅពេលខាងមុខ អាចជួយបង្កើនថវិការដ្ឋាភិបាល សម្រាប់ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈ និងពន្លឿនការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រ។ ទោះយ៉ាងនេះក្តី កម្ពុជាគួរចងចាំថា ប្រទេសសម្បូរធនធាន

---

[១] ដោយលោក **ហេង ឌីណា** និងលោក **ង៉ោ សុថាត** ជាអ្នកស្រាវជ្រាវនៅសមាគមសេដ្ឋកិច្ចកម្ពុជា (CEA)។ អត្ថបទសង្ខេបគោលនយោបាយនេះស្រង់ចេញពីឯកសាររបស់ Heng Dyna and Ngo Sothat (2013), Extractive Industries Revenue Management: Atale of Six Contries, Research Report 4, April 2013 (Phnom Penh: CEA) ដែលជាការសិក្សាស្រាវជ្រាវជាក់ស្តែងមួយបានយកទៅបង្ហាញក្នុងការពិភាក្សាតុមូល និងសិក្ខាសាលាស្តីពី កំណើននិងភាពសម្រាប់គ្រប់គ្នា ក្រោមការសម្របសម្រួលដោយ CEA ដែលជាដៃគូមួយនៅក្នុងវេទិកាស្រាវជ្រាវអភិវឌ្ឍន៍ (DRF)។ របាយការណ៍ពេញលេញមានចុះនៅលើគេហទំព័រ: www.cea.org.kh និង www.crrt-cambodia.org។

[២] ស្រង់ចេញពីសុន្ទរកថាគន្លឹះរបស់ សម្តេចនាយករដ្ឋមន្ត្រី នៅសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០០៨ ក្រោមប្រធានបទ "ការកៀងគរធនធានកម្ពុជាមានធនធានមនុស្ស ធនធានធម្មជាតិ ធនធានហិរញ្ញវត្ថុ សម្រាប់ការអភិវឌ្ឍ កំណើនសេដ្ឋកិច្ច និងវិបុលភាពប្រកបដោយគុណភាព" នៅថ្ងៃទី២៨ កុម្ភៈ ២០០៨ នៅសណ្ឋាគារភ្នំពេញ។

[៣] ប្រេងនៅថ្លៃប្រហែល ១០០ដុល្លារ/ធុង នាពេលបច្ចុប្បន្ន។ អ្នកនិពន្ធបានប្រើថ្លៃប្រយ័ត្នប្រយែងដែលទាបបន្តិចត្រឹម ៥០ដុល្លារ/ធុង ដោយសារការប៉ាន់ស្មានមិនសូវបានច្បាស់ និងថ្លៃឡើងចុះលឿន។

* ចេញផ្សាយដោយ វេទិកាស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា

រូបភាព ២៖ ខ្សែចង្វាក់តម្លៃ និងបញ្ហាប្រឈម




ប្រភព៖ Ross (2012)

នានាតែងជួបនឹងបញ្ហាប្រឈមជាច្រើន មុននឹងទទួលបានជោគជ័យក្នុងការអភិវឌ្ឍសេដ្ឋកិច្ច។

ធនធានធម្មជាតិសម្បូរបែបអាចផ្តល់ទាំងផលល្អនិងផលអាក្រក់។ សេដ្ឋកិច្ចនៃប្រទេសសម្បូរធនធាន ជារឿយៗដំណើរការមិនសូវល្អទេ បើធៀបនឹងប្រទេសប្រហាក់ប្រហែលគ្នា ដែលមិនមានធនធាន។ ទោះបីធនធានទាំងនេះ អាចផ្តល់នូវចំណូលសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសង្គមក្តី ក៏សេដ្ឋកិច្ចអាចមានកំណើនខ្សោយដោយសារ ១) ការបាត់បង់ភាពប្រកួតប្រជែងតាមការឡើងថ្លៃរូបិយវត្ថុក្នុងស្រុក ដែលបង្កឡើងដោយសារលំហូរចូលមូលធន ២) អស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច បង្កឡើងដោយសារមានវដ្តសេដ្ឋកិច្ចស្ទុះរីកដុះដាល និងរលាយអស់ទៅវិញជាញឹកញាប់។ សំណួរមួយចំនួនផុសឡើងថា តើប្រទេសសម្បូរធនធានគួរគ្រប់គ្រងចំណូលរបស់ខ្លួនដោយរបៀបណា? តើប្រទេសទាំងនោះបានជួបបញ្ហាប្រឈមអ្វីខ្លះ? តើកម្ពុជាគួរចាត់វិធានការអ្វីខ្លះនៅពេលនេះ ដើម្បីគ្រប់គ្រងធនធានដ៏សម្បូររបស់ខ្លួនឲ្យមានប្រសិទ្ធភាព និងផលិតភាព ហើយជៀសផុតពី "គ្រោះចង្រៃនៃធនធាន"?

ការយល់ដឹងពីបទពិសោធន៍នៃ ការគ្រប់គ្រងចំណូលពីឧស្សាហកម្មនិស្សារណកម្មនៅតាមប្រទេសនានា ព្រមទាំងជោគជ័យ ឬក៏បរាជ័យផ្សេងៗ មានសារៈសំខាន់បំផុត សម្រាប់អ្នកធ្វើគោលនយោបាយ។ អត្ថបទនេះ ព្យាយាមទាញយកបទពិសោធន៍លើការគ្រប់គ្រងចំណូលប្រេងពីបណ្តាប្រទេសមានកម្រិតអភិវឌ្ឍន៍សេដ្ឋកិច្ច និងអភិបាលកិច្ចប្រហាក់ប្រហែលគ្នា និងផ្តល់ជាអនុសាសន៍ផ្នែក គោលនយោបាយសម្រាប់ការគ្រប់គ្រងចំណូលពី ឧស្សាហកម្មនិស្សារណកម្មនាពេលអនាគតនៅកម្ពុជា។[៤]

## កិច្ចពិភាក្សា

បទពិសោធន៍ពីប្រទេសនានាបង្ហាញថា ការប្រែក្លាយចំណូលបានពីឧស្សាហកម្មនិស្សារណកម្ម ឲ្យទៅជាការអភិវឌ្ឍ វាមិនមែនជាកិច្ចការងាយស្រួលក្នុងរយៈពេលខ្លីនោះទេ។ អភិបាលកិច្ចល្អនៃការគ្រប់គ្រងចំណូលពីឧស្សាហកម្មនិស្សារណកម្ម មានសារៈសំខាន់តាំងពីដំបូងដៃ ចាប់តាំងពីការរុករកប្រេង រហូតដល់ការដេញថ្លៃ និងចុះកិច្ចសន្យា, ការជ្រើសយកគំរូចំណាយ-សន្សំ, ចីរភាពហិរញ្ញវត្ថុ, និងគោលនយោបាយអភិវឌ្ឍន៍រយៈពេលវែង។ ដើម្បីឲ្យធនធានប្រេង ឧស្ម័ន និងរ៉ែ មានផលប្រយោជន៍ល្អដល់ជាតិ ប្រទេសសម្បូរធនធាននានា ត្រូវដោះស្រាយបញ្ហាប្រឈមជាច្រើនទាំងផ្នែកសេដ្ឋកិច្ច និងស្ថាប័ន។

អត្ថបទនេះផ្តោតលើការគ្រប់គ្រងចំណូល និងចំណាយ ដែលជាផ្នែកមួយនៃខ្សែចង្វាក់តម្លៃ (រូបភាព ២)។ បន្ទាប់ពីប្រមូលចំណូលបានហើយ រដ្ឋាភិបាលត្រូវសម្រេចចិត្តលើការគ្រប់គ្រង និងការបែងចែក ពោលគឺ តើត្រូវចាយប៉ុន្មាន និងទៅលើអ្វី។ ក្នុងកិច្ចការនេះ គំរូសេដ្ឋកិច្ចនៃការចាយវាយសំខាន់ជាខ្លាំង ពីព្រោះវាផ្សារភ្ជាប់ផ្ទាល់ទៅនឹងមាគ៌ាអភិវឌ្ឍន៍របស់ប្រទេស ហើយនិង "គ្រោះចង្រៃនៃធនធាន"។ ជាទូទៅ ក្នុងការគ្រប់គ្រងចំណូលបានពីធនធានធម្មជាតិ រដ្ឋាភិបាលត្រូវដោះស្រាយបញ្ហាមួយចំនួនដូចតទៅ៖

- តម្រូវការផ្សេងៗសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និង សង្គម
- ជម្រើសរវាងផលប្រយោជន៍ក្នុងពេលបច្ចុប្បន្ន និងទៅអនាគត (សមភាពរវាងជំនាន់មនុស្ស)
- ការរចនារៀបចំគោលនយោបាយសម្រាប់ទប់ទល់នឹងការឡើងចុះថ្លៃ និងការរេចរិលធនធានធម្មជាតិ
- ការពង្រឹងសមត្ថភាពក្នុងស្រុក ដើម្បីស្រូបយកការចំណាយនូវប្រាក់ចំណូលបានពីធនធាន
- តម្លាភាពនិងគណនេយ្យភាព។

ការគិតគូរពិចារណាទាំងនេះ ត្រូវតែធ្វើឡើងដោយមានគោលនយោបាយណែនាំពី វិធីចាយវាយប្រាក់ចំណូលបានពីប្រេងឲ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាព សម្រាប់កំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ។ ជាទូទៅ បញ្ហាចម្បងគេបីដែលត្រូវដោះស្រាយដោយប្រុងប្រយ័ត្ន ដើម្បីញ៉ាំងឲ្យចំណាយសាធារណៈមានចីរភាពទៅអនាគត គឺ៖ (១) វិន័យសារពើពន្ធ (២) ប្រសិទ្ធភាពនៃការបែងចែក និង (៣)ប្រសិទ្ធភាពនៃប្រតិបត្តិការចំណាយ។

ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ ប្រទេសសម្បូរធនធានអាចអនុវត្តតាមគំរូចំណាយ-សន្សំមួយចំនួនដូចមានបង្ហាញក្នុងតារាង ១។ ការជ្រើសយកគំរូណាមួយមកអនុវត្ត ត្រូវផ្អែកទៅតាមដំណាក់កាលអភិវឌ្ឍន៍របស់ប្រទេសនីមួយៗ និងសេដ្ឋកិច្ចនយោបាយ។

## គុណភាពស្ថាប័ន និងគោលនយោបាយ

ការពិនិត្យលើបទពិសោធន៍ប្រទេសទាំងប្រាំមួយ បានបង្ហាញថា ចំណូលពីធនធានធម្មជាតិអាចគ្រប់គ្រងបាន និងអាចមានប្រយោជន៍សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច។ ទោះយ៉ាងនេះក្តី គេត្រូវអនុវត្តនូវគោលនយោបាយត្រឹមត្រូវ និងចម្រុះមុខ រួមមាន គោលនយោបាយគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច សារពើពន្ធ និងអត្រាប្តូរប្រាក់ ដើម្បីកាត់

[៤] ប្រទេសទាំងនេះរួមមាន អាស៊ែបៃហ្សង់, ហ្គាណា, ឥណ្ឌូនេស៊ី, នីហ្សេរីយ៉ា, ទីម័រខាងកើត, និង វៀតណាម។ ប្រទេសទាំងនេះត្រូវបានជ្រើសយក តាមការពិគ្រោះយោបល់ជាមួយអាជ្ញាធរពាក់ព័ន្ធនឹងអង្គការសង្គមស៊ីវិលនៅកម្ពុជា ដោយផ្អែកលើសូចនាករសំខាន់ៗមួយចំនួន មានជាអាទិ៍ ផសស ក្នុងមនុស្សម្នាក់, អត្រាភាពក្រីក្រ, វិសមភាពប្រាក់ចំណូល, លទ្ធផលផ្នែកហិរញ្ញវត្ថុ, និងកម្រិតអភិបាលកិច្ច។

តារាង ១៖ គំរូចំណាយ-សន្សំ

| គំរូ | និយមន័យ | ផលប្រយោជន៍ | ហានិភ័យ |
|---|---|---|---|
| ចំណាយជម្រុញខ្លាំង<br>Big-Push Spending | ចំណាយនូវប្រាក់ចំណូលបច្ចុប្បន្នទាំងអស់ ឬភាគច្រើន | បង្កើនល្បឿនកំណើនសេដ្ឋកិច្ច និងអាចកាត់បន្ថយភាពក្រីក្របានកាន់តែលឿន | ចំណាយរដ្ឋគ្មានស្ថិរភាព, អស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិង "ជម្ងឺហូឡង់"[៥] ដោយសារការឡើងចុះថ្លៃប្រេង |
| បក្សីក្នុងដៃ<br>Bird-in-Hand | ចាយតែប្រាក់ចំណូលបានពីទ្រព្យសម្បត្តិបច្ចុប្បន្ន[៦] | របបសន្សំសំចៃសាមញ្ញ និងប្រុងប្រយ័ត្ន | បាត់បង់ឱកាសកំណើន ដោយសារពុំបានវិនិយោគលើរចនាសម្ព័ន្ធនិងសង្គម |
| ចំណូលមានចីរភាព<br>Sustainable Income | ចំណូលពិតពីទ្រព្យសម្បត្តិបច្ចុប្បន្ននិងទៅអនាគត | ចំណាយដោយប្រើចំណូលបានពីធនធានធម្មជាតិ មានស្ថិរភាពល្អ និងចៀសវាងបាននូវខួបឡើងចុះនៃសេដ្ឋកិច្ច | ភាពមិនច្បាស់លាស់ក្នុងការប៉ាន់ស្មានចំណូល ដោយសារភាពមិនច្បាស់លាស់នៃថ្លៃប្រេង និងបរិមាណប្រេងក្នុងដី |
| កំណត់ចំណូលគោល<br>Revenue Benchmarking | ចំណាយមួយចំណែក (ថេរ ឬអថេរ) នៃចំណូលមធ្យមលើទ្រព្យសម្បត្តិ (មធ្យមភាគរំកិល) | មុខងារអាចបត់បែនបាន (បង្កស្ថិរភាព និងការសន្សំសំចៃ) | មិនធានាថា ហិរញ្ញវត្ថុមានចីរភាព ឬការប្រើប្រាស់ធនធានធ្វើបានល្អបំផុតពីមួយជំនាន់ទៅមួយជំនាន់នោះទេ ព្រោះផ្អែកលើការសម្រេចចិត្ត។ ត្រូវមានការកំណត់ច្បាស់នូវចំណូលគោល និងគោលដៅអភិវឌ្ឍន៍រយៈពេលវែង |

ប្រភព៖Heng and Ngo (2013: 2-3)

បន្ថយឥទ្ធិពលជម្ងឺហូឡង់ និងធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ អភិបាលកិច្ចល្អលើឧស្សាហកម្មនិស្សារណកម្ម តម្រូវឲ្យមានផែនការរយៈពេលវែង តាំងពីការអភិវឌ្ឍក្នុងដំណាក់កាលដំបូង ព្រមទាំងតម្លាភាពសារពើពន្ធក្នុងរយៈពេលវែង។

ជារួម គុណភាពស្ថាប័នជាកត្តាសំខាន់បំផុតសម្រាប់ការប្រើប្រាស់ចំណូលពី ឧស្សាហកម្មនិស្សារណកម្មឲ្យមានប្រយោជន៍។ ការគ្រប់គ្រងល្អ អាស្រ័យជាសំខាន់លើ គុណភាពនៃការចំណាយហិរញ្ញវត្ថុ និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈមានចីរភាពល្អពីរបបនយោបាយមួយ ទៅរបបមួយទៀត ពោលគឺ ប្រទេសមួយត្រូវមានផែនការរយៈពេលវែង មានផែនការរយៈពេលមធ្យម និងមានការកំណត់ច្បាស់ពីអាទិភាពសម្រាប់ការអភិវឌ្ឍ និងតម្រូវការហិរញ្ញវត្ថុ។ យុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រកបដោយជោគជ័យ តែងមានសមាសធាតុ៣ជាសំខាន់៖

១) ផែនការវិនិយោគសាធារណៈយូរអង្វែង និងសមស្របតាមលក្ខខណ្ឌក្នុងស្រុក

២) ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច ដើម្បីលើកកម្ពស់ដល់វិស័យឯកជន

៣) ក្របខ័ណ្ឌនយោបាយ ដើម្បីធានាឲ្យមាននីតិរដ្ឋ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។

គំរូសន្សំ-ចំណាយគួរអនុម័តយក ដោយផ្អែកលើដំណាក់កាលនៃការអភិវឌ្ឍសេដ្ឋកិច្ច គុណភាពស្ថាប័ន និងទំហំ និងលក្ខណៈនៃលំហូរប្រាក់ចំណូលបានពីធនធានធម្មជាតិ។ ជាងនេះទៅទៀត ដោយសារឧស្សាហកម្មនិស្សារណកម្ម តែងផ្សារភ្ជាប់ខ្លាំងទៅនឹងទីតាំងនីមួយៗ និងមានផលប៉ះពាល់ជាច្រើនដល់សហគមន៍មូលដ្ឋាន ដូច្នេះប្រទេសនានាត្រូវមានការគ្រប់គ្រងចំណូលប្រកបដោយប្រសិទ្ធភាព ដើម្បីកាត់បន្ថយគម្លាតក្នុងផ្ទៃប្រទេស ជាពិសេសរវាងតំបន់សម្បូរធនធាន និងតំបន់ខ្សត់ធនធាន។ រដ្ឋបាលថ្នាក់ក្រោមជាតិដើរតួនាទីសំខាន់បំផុតក្នុងការគ្រប់គ្រងឲ្យមានសមធម៌នូវចំណូលបានពីធនធានធម្មជាតិ។

## ផលពាក់ព័ន្ធដល់គោលនយោបាយ

ត្រូវមានការវិភាគស៊ីជម្រៅមួយ ដោយផ្អែកលើទិន្នន័យគួរជឿជាក់ និងរចនាសម្ព័ន្ធហិរញ្ញវត្ថុសាធារណៈ ដើម្បីផ្តល់អនុសាសន៍ថា តើកម្ពុជាគួរចំណាយទៅលើអ្វី និងចំនួនប៉ុន្មាន។ ប៉ុន្តែដោយផ្អែកលើការសិក្សាអំពីទ្រឹស្តី និងការអនុវត្តជាក់ស្តែងក្នុងប្រទេសមួយចំនួន កម្ពុជាគួរគិតគូរទៅលើជម្រើសដូចខាងក្រោម៖

- ថ្លឹងថ្លែងឲ្យមានតុល្យភាពល្អ រវាងការសន្សំ និងចំណាយ យោងតាមតម្រូវការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងសង្គម។ ប៉ុន្តែកម្ពុជា ក៏មានហេតុផលច្រើនដែលត្រូវសន្សំទុកចំណូលមួយផ្នែកដែរ យ៉ាងហោចណាស់សម្រាប់ការរក្សាស្ថិរភាព ពីព្រោះកម្ពុជា

[៥] "ជំងឺហូឡង់" ជាផលប៉ះពាល់អវិជ្ជមានទៅលើសេដ្ឋកិច្ចនៃកត្តាអ្វីមួយដែលបង្កលំហូរចូលយ៉ាងគំហុកនូវរូបិយវត្ថុបរទេស ដូចជាការរកឃើញធនធានប្រេងយ៉ាងធំជាដើម។ លំហូររូបិយវត្ថុនេះធ្វើឲ្យរូបិយវត្ថុក្នុងស្រុកឡើងថ្លៃ ហើយផលិតផលផ្សេងៗរបស់ប្រទេសនោះក៏មានថ្លៃមិនប្រកួតប្រជែងនៅក្នុងទីផ្សារនាំចេញ។ វាក៏នាំឲ្យមានទំនិញនាំចូលថោកៗ ដូច្នេះហើយឧស្សាហកម្មផ្សេងៗក្រៅពីការធ្វើអាជីវកម្មលើធនធានធម្មជាតិក៏បាត់បង់អស់ទៅ ព្រោះត្រូវផ្លាស់ទីទៅរកកន្លែងមានតម្លៃថោកជាង (http://lexicon.ft.com/Term?term=dutch-disease)។

[៦] រដ្ឋាភិបាលដាក់ចំណូលពីប្រេងកាតទាំងអស់ទៅក្នុងមូលនិធិមួយ ហើយក្នុងមួយឆ្នាំៗអាចដកយកនូវភាគរយ (កំណត់ច្បាស់ជាមុន) ណាមួយនៃមូលនិធិក្នុងឆ្នាំមុន ដើម្បីបញ្ចូលទៅក្នុងថវិការដ្ឋ។

នៅមានសមត្ថភាពស្ថាប័នទន់ខ្សោយ និងការប្រមូលពន្ធ នៅមានកម្រិត។ ក្រុមអ្នកនិពន្ធយល់ថា កម្ពុជាគួរពិចារណាអនុវត្តតាមគំរូកំណត់ចំណូលគោល ដែលក្នុងនោះ រដ្ឋាភិបាលអាចកំណត់យកចំណូលមួយភាគ (ថេរ ឬអថេរ) នៃចំណូលមធ្យម ហើយចំណូលនៅសល់ ត្រូវយកទៅសន្សំទុកនៅក្នុងមូលនិធិរក្សាស្ថិរភាពមួយ។

- កំណត់ឲ្យកិច្ចសន្យាប្រេងទាំងអស់មានស្តង់ដារតែមួយ ដើម្បីកាត់បន្ថយភាពស្មុគស្មាញនៃលំហូរចំណូល៖ កម្ពុជាគួរមានលក្ខខណ្ឌកិច្ចសន្យាស្តង់ដារមួយ ដែលជួយឲ្យរដ្ឋាភិបាលងាយស្រួលក្នុងការពិនិត្យតាមដានកិច្ចសន្យានានា។ បទពិសោធន៍នៅប្រទេសជាច្រើនបង្ហាញថា ដរាបណាដំណាក់កាលមានកាន់តែច្រើនរវាងការបង្កើតចំណូល និងការទទួលបានចំណូលដោយរដ្ឋាភិបាលនោះ ឱកាសធ្លាយបាត់ចំណូលក៏កាន់តែមានច្រើនដែរ។
- កសាងសមត្ថភាពពិនិត្យតាមដានផលិតកម្ម៖ អាជ្ញាធរពាក់ព័ន្ធត្រូវទទួលបានការបណ្តុះបណ្តាលយ៉ាងល្អ ដើម្បីពិនិត្យតាមដានផលិតកម្ម និងការនាំចេញនៃឧស្សាហកម្មនិស្សារណកម្ម បើពុំនោះទេ រដ្ឋាភិបាលនឹងត្រូវតែជឿតាមតួលេខទាំងអស់ ដែលក្រុមហ៊ុនផ្តល់ឲ្យ។
- កំណត់តួនាទីច្បាស់លាស់របស់បណ្តាស្ថាប័នរដ្ឋពាក់ព័ន្ធ៖ ស្ថាប័នរដ្ឋជាប់ពាក់ព័ន្ធទាំងអស់ (មិនមែនមានតែអាជ្ញាធរប្រេងកាតមួយនោះទេ) ត្រូវកសាងសមត្ថភាព និងមានតួនាទីច្បាស់លាស់នៅក្នុងលំហូរចំណូល និងចំណាយ។ ទន្ទឹមគ្នានេះ ស្ថាប័នសារពើពន្ធនានារបស់កម្ពុជា ត្រូវពង្រឹងសមត្ថភាពបន្ថែម ដើម្បីគ្រប់គ្រងចំណូលពីធនធានធម្មជាតិឲ្យមានប្រសិទ្ធភាព។
- លើកកម្ពស់តម្លាភាព និងគណនេយ្យភាពថវិកា៖ តម្លាភាព និងគណនេយ្យភាពថវិកាសំខាន់បំផុត ក្នុងការគ្រប់គ្រងចំណូលពីធនធានធម្មជាតិ។ ក្នុងនេះ ក្រុមប្រឹក្សាត្រួតពិនិត្យមួយដែលមានតំណាងមកពីរដ្ឋាភិបាលដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល អាចជួយលើកកម្ពស់តម្លាភាព និងគណនេយ្យភាពក្នុងការគ្រប់គ្រងចំណូលបានពីធនធានធម្មជាតិនៅប្រទេសកម្ពុជា។ ជម្រើសមួយសម្រាប់ប្រទេសកម្ពុជា គឺការចូលជា សមាជិកអង្គការគំនិតផ្តួចផ្តើមតម្លាភាពឧស្សាហកម្មនិស្សារណកម្ម (EITI) ដើម្បីអាចបានរៀនសូត្រពីបទពិសោធន៍ល្អៗនៅប្រទេសឯទៀត ហើយធ្វើការគ្រប់គ្រងចំណូលពីប្រេងឲ្យមានតម្លាភាព។

**ឯកសារស្រាវជ្រាវបន្ថែម**
**(សូមអានឯកសារភាសាអង់គ្លេស)**

## អំពីវេទិកាស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា

វេទិកាសិក្សាស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា (DRF) បានកកើតឡើងក្រោយពេលដែល មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិ (IDRC) រៀបចំវេទិកាស្ថាប័នដៃគូទាំងអស់មួយ នៅខែកញ្ញា ឆ្នាំ២០០៧។

ទស្សនៈវិស័យរបស់ DRF គឺលើកកម្ពស់សហគមន៍ស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជាឲ្យមានគុណភាពខ្ពស់ និងប្រកបដោយវិជ្ជាជីវៈ ព្រមទាំងមានគោលបំណងទ្រទ្រង់ និងពង្រឹងសមត្ថភាពរបស់សហគមន៍ស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា។

ដៃគូក្នុង DRF មាន វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ/CDRI), សមាគមសេដ្ឋកិច្ចកម្ពុជា (CEA), វិទ្យាស្ថានសិក្សាស្រាវជ្រាវ និង បណ្តុះបណ្តាល (LI), វិទ្យាស្ថានជាតិសុខភាពសាធារណៈ (NIPH), សាកលវិទ្យាល័យភូមិន្ទកសិកម្ម (RUA), សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP), ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC), និង មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិ (IDRC)។

ក្នុង DRF ដំណាក់កាលទី២ ដោយបានទទួលជំនួយហិរញ្ញវត្ថុពី IDRC ដៃគូទាំងអស់ធ្វើការយ៉ាងសកម្ម ដើម្បីកសាងវប្បធម៌ស្រាវជ្រាវ និងសមត្ថភាពស្រាវជ្រាវ ព្រមទាំងចែករំលែកចំណេះដឹងគ្នាទៅវិញទៅមកតាមរយៈ សិក្ខាសាលា កិច្ចប្រជុំតុមូល ការបណ្តុះបណ្តាល និងពិភាក្សាតាមអ៊ីនធឺណែត (www.drfcambodia.net) ក្រោម ៦ ប្រធានបទ៖ កំណើនសម្រាប់គ្រប់គ្នា, អភិបាលកិច្ចធនធានធម្មជាតិ, គោលនយោបាយសង្គមកិច្ចស្តីពីការអប់រំ, គោលនយោបាយសង្គមកិច្ចស្តីពីសុខាភិបាល, ការអភិវឌ្ឍកសិកម្ម, និង ប្រទេសកម្ពុជានិងតំបន់ជុំវិញ។

## ក្នុងនាមជាដៃគូនៃ

សមាគមសេដ្ឋកិច្ចកម្ពុជា
CAMBODIAN ECONOMIC ASSOCIATION
THE LEARNING INSTITUTE
ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
Supreme National Economic Council
IDRC | CRDI


**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ/CDRI)**

☞ 56 ផ្លូវ 315, ខណ្ឌទួលគោក ✉ ប្រអប់សំបុត្រលេខ 622, ភ្នំពេញ កម្ពុជា
☎ (855 23) 881 384/881 701/881 916/883 603 🖷 (855 23) 880 734
អ៊ីមែល: cdri@cdri.org.kh, គេហទំព័រ: www.cdri.org.kh